ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ០៥៣/..........គ.ជ.ប.ជ

# របាយការណ៍បូកសរុប
## សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខែកុម្ភៈ និងទិសដៅខែមីនា ឆ្នាំ២០១៨

## I. ស្ថានភាពទូទៅ

ក្នុងខែកុម្ភៈ ឆ្នាំ២០១៨ ស្ថានភាពបទល្មើសជួញដូរមនុស្ស ត្រូវបានបង្ការ ទប់ស្កាត់ និងបង្ក្រាបជាបន្តបន្ទាប់ ដោយមានការខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង និងមានការសហការគ្នាបានល្អ រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាមួយស្ថាប័ន អន្តរក្រសួង និងអង្គភាពពាក់ព័ន្ធនានា ជាពិសេសលេខាធិ ការដ្ឋាន គ.ខ.ប.ជ ថ្នាក់ក្រោមជាតិ។ ដោយឡែកការធ្វើចំណាកស្រុកឆ្លងដែន ឬទេសន្តរប្រវេសន៍ ក៏មានស្ថានភាពមិនប្រក្រតី រហូតដល់រាជរដ្ឋាភិបាលកម្ពុជាដែលមានសម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ បានមានប្រសាសន៍នៅក្នុងកម្មវិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ប្រចាំ ២០១៧ របស់រដ្ឋបាលខេត្តបាត់ដំបង និងបញ្ជាក់ថា "**ឆ្នាំ២០១៨ ត្រូវបិទច្រករបៀងឲ្យបាន**" ពីព្រោះវាមិនមែនតែទំនិញគេចពន្ធ និងគ្រឿងញៀនទេ វាជាច្រកមានការរត់ពន្ធមនុស្ស ជួញដូរមនុស្ស ដែលជាបញ្ហាគ្រោះថ្នាក់ដល់ប្រជាពលរដ្ឋយើងត្រូវបានគេនាំចេញទៅធ្វើការនៅប្រទេសថៃដោយខុសច្បាប់ រហូតដល់ជាងមួយលាននាក់ ទាំងស្របច្បាប់ ទាំងមិនមានឯកសារច្បាស់លាស់ និងការខាតបង់ថវិកាជាតិរាប់លានដុល្លារ។ ក្រោយពីរាជរដ្ឋាភិបាលថៃបានចេញគោលការណ៍រឹតបន្តឹងពលករទេសន្តរប្រវេសន៍ ធ្វើការខុសច្បាប់ក្នុងប្រទេសថៃរួចមក ដើម្បីជាដំណោះស្រាយ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា បានយកចិត្តទុកដាក់បំផុតចំពោះប្រជាពលរដ្ឋ ធ្វើទេសន្តរប្រវេសយ៍នៅក្រៅប្រទេស និងបានសហការជាមួយរដ្ឋាភិបាលថៃ ក្នុងការជំរុញឲ្យមានការរៀបចំផ្តល់ភាពស្របច្បាប់ដល់ពលករកម្ពុជា ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ជាពិសេសត្រូវបានពិភាក្សាជាមួយភាគីថៃ ដើម្បីការការពារសុវត្ថិភាព សិទ្ធិការងារ ក្នុងនោះរួមមានរបបគ្រោះថ្នាក់ការងារ របបថែទាំសុខភាព និងប្រាក់សោធននិវត្តន៍ជូនដល់ពលករកម្ពុជា ឲ្យដូចពលករថៃដែរ។

បន្ទាប់ពីការពិភាក្សាគ្នារវាងក្រសួងការងារនៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងការងារនៃព្រះរាជាណាចក្រថៃ។ រាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលថៃ បានសម្រេចបន្ថែមការិយាល័យត្រួតសញ្ជាតិ ធ្វើប៉ាស្ព័រជូនបងប្អូនពលករខ្មែរ ដែលកំពុងធ្វើការនៅក្នុងប្រទេសថៃ ចំនួនជាច្រើនកន្លែងទៀត ព្រមទាំងមានភ្នាក់ងារចល័តចុះត្រួតសញ្ជាតិ ធ្វើប៉ាស្ព័រជូនបងប្អូនពលករកម្ពុជា នៅក្នុងតំបន់ដែលមានបងប្អូនរស់នៅច្រើន ដូចជាខេត្តនុនថាកបុរី ឈុនបុរី បាធុមថានី និងខេត្តសាមុតប្រាកានជាដើម ដើម្បីជួយសម្រួលភាពស្របច្បាប់ជូនពលករកម្ពុជាទាំងអស់ដែលមិនបានត្រួតសញ្ជាតិធ្វើប៉ាស្ព័រនៅក្នុងប្រទេសថៃ។ ក្រោយពីពលករកម្ពុជាទាំងអស់បានចូលទៅបញ្ជាក់អត្តសញ្ញាណធ្វើប៉ាស្ព័រ ត្រូវបាន Tha

រាជរដ្ឋាភិបាលថៃប្រកាសឲ្យបន្តធ្វើប័ត្រស៊ីជម្ពូជូនគ្រប់ៗគ្នា ដើម្បីបន្តសុពលភាពស្នាក់នៅបន្តទៅមុខទៀត បន្ទាប់មក និងមានការិយាល័យមួយចំនួនត្រៀមនឹងបើកដំណើរការបន្ថែម ក្នុងពេលឆាប់ៗខាងមុខនេះ។

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន **គ.ជ.ប.ជ** ជាសេនាធិការ បានបន្តសម្របសម្រួល ពង្រឹងកិច្ចសហការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ ប្រមូលផ្តុំកម្លាំងចូលរួមរបស់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព រាជធានី-ខេត្ត ដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរកដំណោះស្រាយបញ្ហាប្រឈមនានា។ របាយការណ៍ដែលអគ្គលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទទួលបាន ៖

- ពីបណ្តាក្រសួង ស្ថាប័ន ថ្នាក់ជាតិ មានក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការពារជនរងគ្រោះ) ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) អគ្គនាយកដ្ឋានអន្តោប្រវេសន៍ កងរាជអាវុធហត្ថលើផ្ទៃប្រទេស។
- សម្រាប់បណ្តាស្ថាប័ន ថ្នាក់ក្រោមជាតិ មានលេខាធិការដ្ឋាន**២៤**រាជធានី-ខេត្ត បានផ្តល់របាយការណ៍។ ដោយឡែកខេត្តកំពតមិនបានផ្តល់របាយការមកលេខាធិការដ្ឋាន គ.ជ.ប.ជ។

ជាលទ្ធផល ដែលសម្រេចបានក្នុងខែកុម្ភៈ ឆ្នាំ២០១៧នេះ មានដូចខាងក្រោម៖

# ការអនុវត្តផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ (២០១៤-២០១៨)

## ក. ពង្រឹងការអនុវត្តច្បាប់ គោលនយោបាយ និងលើកកម្ពស់សហប្រតិបត្តិការ

### ក.១-ការងារច្បាប់ គោលនយោបាយលិខិតបទដ្ឋានជាតិ និងកិច្ចសហប្រតិបត្តិការ

#### ក.១-ច្បាប់ គោលនយោបាយលិខិតបទដ្ឋានជាតិ និងកិច្ចសហប្រតិបត្តិការកំពុងរៀបចំ

**ក.១.១-សេចក្តីព្រាងច្បាប់ដែលកំពុងរៀបចំ៖**

- សេចក្តីព្រាងច្បាប់ ស្តីពី"**ការពពោះជំនួស**"(ក្រសួងកិច្ចការនារី និងក្រសួងយុត្តិធម៌)។
- **ក្រសួងយុត្តិធម៌**បានរៀបចំសេចក្តីព្រាងច្បាប់ចំនួន០២គឺ៖
    - ស្តីពី"**ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ**" (MLA)
    - ស្តីពី "**ការប្រឆាំងអំពើរត់ពន្ធមនុស្ស**"។

**ក.១.២-លិខិតបទដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិកំពុងរៀបចំ៖**

- **ក្រសួងយុត្តិធម៌** បានរៀបចំសេចក្តីព្រាងចុះលើសន្ធិសញ្ញា ទ្វេភាគីរួមមាន៖
    - **សេចក្តីព្រាងសន្ធិសញ្ញា ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"**
      រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ
      រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលបារាំង
      រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលកូរ៉េខាងត្បូង។
    - **សេចក្តីព្រាង កិច្ចព្រមព្រៀង ស្តីពី "បញ្ជូនទណ្ឌិត"**
      រវាងព្រះរាជាណាចក្រកម្ពុជា និង រដ្ឋាភិបាលអង់គ្លេស
      រវាងព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលប៉េរូ
      រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋប្រជាមានិតឡាវ។

**ក.១.៣-លិខិតបទដ្ឋានជាតិកំពុងរៀបចំ៖**

- សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្តិ "**សម្រាប់អនុវត្តលក្ខខណ្ឌការងារកម្មករការងារផ្ទះ**" (ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ)។

- សេចក្តីព្រាងគោលនយោបាយ ស្តីពី "**កិច្ចការការពារកុមារតាមសាលារៀន**" (ក្រសួងអប់រំយុវជន និងកីឡា)។
- សេចក្តីព្រាងរៀបចំអនុក្រិត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍ (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា)។

❖ **អនុស្សរណៈរវាងអង្គការដៃគូដែលបានចុះហត្ថលេខារួចហើយ៖**

- **គណៈកម្មាធិការជាតិ គ.ជ.ប.ជ** បានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយសមាគមមូលនិធិ **ឈាន ឆាយ** ដើម្បីមនុស្សធម៌ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស នៃពលករទេសន្តរប្រវេសន៍ នៅប្រទេសថៃ នៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១៨។

❖ **អនុស្សរណៈរវាងអង្គការដៃគូកំពុងរៀបចំ៖**

- **គណៈកម្មាធិការជាតិ គ.ជ.ប.ជ** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយអង្គការអន្តរជាតិ GVC ស្តីពីការគាំទ្រ និងការតស៊ូមតិលើសិទ្ធិពលករទេសន្តរប្រវេសន៍ កម្ពុជា ក្នុងប្រទេសថៃ ដើម្បីទប់ស្កាត់ការរំលោភបំពានអំពើជួញដូរមនុស្ស។
- **ក្រសួងទេសចរណ៍** ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាពជាមួយអង្គការ Friends International។
- **ក្រសួងសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** បានប្រជុំថ្នាក់មន្ត្រីបច្ចេកទេសលើកទី៤ និងថ្នាក់រដ្ឋមន្ត្រីលើកទី២ ស្តីពីការអនុវត្តអនុស្សរណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសម៉ាឡេស៊ី ស្តីពីការជ្រើសរើស ការបញ្ជូន និងការគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅប្រទេសម៉ាឡេស៊ី នៅសណ្ឋាគារសូហ្វីតែលភ្នំពេញ។

## ខ.ការបង្ការទប់ស្កាត់

### ខ.១-កាត់បន្ថយភាពរងគ្រោះដល់ជនមុខសញ្ញារងគ្រោះ៖

- **ខេត្តបន្ទាយមានជ័យ** ប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ មានប៉ុស្តិ៍ច្រកទ្វារៈបោយប៉ែត ម៉ាឡៃ និងច្រកទ្វារបឹងត្រកួន បានជួយសម្រួលនិងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ចំនួន**៣៦២៦**ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន ។
- **ខេត្តបាត់ដំបង** ប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ មានប៉ុស្តិ៍ច្រកទ្វារភ្នំដី(គីឡូ១៣) បានជួយសម្រួល និងផ្តល់ប័ណ្ណព្រំដែនកម្ពុជា-ថៃ ចំនួន**១៣០**ប័ណ្ណ ដល់ពលរដ្ឋខ្មែរដែលរស់នៅក្នុងខេត្តជាប់ព្រំដែន។

### ខ.២-ការអប់រំ ផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ

នៅខែកុម្ភៈ ឆ្នាំ២០១៨នេះ **ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ** អាជ្ញាធរ មន្ទីរពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ចសហការជាមួយអង្គការដៃគូ បានធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងវេទិកាសាធារណៈ ក្នុងការអនុវត្តគោលនយោលបាយ "**ភូមិ-ឃុំមានសុវត្ថិភាព**" ដល់អាជ្ញាធរមូលដ្ឋាន សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ និងប្រជាពលរដ្ឋ បានចំនួន**៥.៥២៣**លើក មានអ្នកចូលរួមសរុបចំនួន**៣២៣.៨២២**នាក់ (បើប្រៀបធៀបនឹងខែមុន មានចំនួនត្រឹមតែ**២៦៧.១១៥**នាក់) កើនឡើងចំនួន**៥៦.៧០៧**នាក់ ស្មើនឹង**២១.២២%** ក្នុងនោះស្ត្រីមានចំនួន**១៦៦.៧៩៤**នាក់។ (**ឧបសម្ព័ន្ធទី១**) Tha

## ៤.៣-ការផ្សព្វផ្សាយតាមរយៈសម្ភារៈ និងតាមប្រព័ន្ធព័ត៌មាន

- **លេខាធិការដ្ឋាន គ.ជ.ប.ជ ខេត្ត** បានចូលរួមផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស តាមប៉ុស្តិ៍វិទ្យុចំនួន៤៧លើក (ខេត្តកោះកុង២៨លើក, សៀមរាប១៨លើក និងបាត់ដំបង០១លើក)។
- **ខេត្តបាត់ដំបង អង្គការ Samaritan Purse** បានសហការជាមួយសមត្ថកិច្ច ចែកខិត្តប័ណ្ណផ្សព្វផ្សាយដល់ពលករចំណាកស្រុក៣៤នាក់ ស្រី១០នាក់ ដែលបញ្ជូនត្រឡប់នៅព្រំដែនប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ មកដល់ស្រុកកំណើតវិញ។

## ៤.៤-ទប់ស្កាត់ រារាំងតម្រូវការសេវាកម្ម ដែលទំនោរទៅរកការជួញដូរមនុស្ស

### ៤.៤.១.-វិធានការទប់ស្កាត់តាមជំនាញរបស់អគ្គស្នងការនគរបាលជាតិ

- **ស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ** បានធ្វើការទប់ស្កាត់ពលករខ្មែរ ដែលបំរុងធ្វើចំណាកស្រុកខុសច្បាប់ ទៅធ្វើការនៅប្រទេសថៃ បានចំនួន០១លើក មនុស្សចំនួន០២នាក់(អនីតិជន)។

### ៤.៤.២-វិធានការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ៖

អគ្គស្នងការដ្ឋាននគរបាលជាតិ (**របាយការណ៍ពីក្រុមការងារអនុវត្តន៍ច្បាប់**) និងស្នងការរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាពបង្ការ ទប់ស្កាត់តាមគោលដៅ ទទួលបានលទ្ធផលដូចខាងក្រោម៖

- បច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម និងបុគ្គលិកធ្វើការក្នុងហាងម៉ាស្សា ខារ៉ាអូខេ បានចំនួន**៥២៣**គោលដៅ មានមនុស្សចំនួន**១.៧៥៣**នាក់ (ស្រី **១.៣២៧**នាក់) **កម្លាំងជំនាញអនុវត្ត នៃស្នងការដ្ឋាននគរបាលខេត្ត មានខេត្ត៖** (តាកែវ មណ្ឌលគិរី កំពត កែប ស្ទឹងត្រែង ពោធិ៍សាត់ កំពង់ចាម និងកំពង់ឆ្នាំង)។
- គោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ក្នុងនោះអំពើជួញដូរមនុស្សចំនួន០៩គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទចំនួន**៦៦**គោលដៅ សរុបចំនួន**៧៥**គោលដៅទូទាំងរាជធានី-ខេត្ត។
- ការល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពធ្វើអាជីវកម្មផ្លូវភេទ ធ្វើបានចំនួន**២២**លើក ខេត្តអនុវត្តមាន៖ ស្វាយរៀង ឧត្តរមានជ័យ ព្រះវិហារ និងព្រៃវែង។

## ៤.៥-គោលនយោបាយប្រឆាំងនឹងទេសន្តរប្រវេសន៍ខុសច្បាប់ និងគ្រោះថ្នាក់

### ៤.៥.១-វិធានការគ្រប់គ្រងបច្ចុប្បន្នភាពចំណាកស្រុក

- បានធ្វើបច្ចុប្បន្នភាពទិន្នន័យពលករចំណាកស្រុកទៅក្រៅប្រទេស សរុបចំនួន**២៨៨.២៦៣**នាក់ (ស្រី**១២៦.៨២៩**នាក់) អនីតិជន**៨.៥១៣**នាក់ (ស្រី**៣.១៦៦**នាក់) ក្នុងនោះស្របច្បាប់ចំនួន **១៥៧.១៤៧**នាក់ (ស្រី**៧៣.៦៥៨**នាក់) អនីតិជន**៩៩៧**នាក់ (ស្រី**៤២៧**នាក់) មិនស្របច្បាប់ចំនួន**១៣១.១១៦**នាក់ (ស្រី**៥៣.១៧១**នាក់) អនីតិជន**៧.៥១៦**នាក់ (ស្រី**២.៧៣៩**នាក់) បើប្រៀបធៀបនឹងខែមុនមានការថយមានចុះចំនួន**១១.៨១៤**នាក់ ស្មើនឹង**៣.៩៣%**។

### ៤.៥.២-ការតាមដានស្ថិតិពលករ ដែលត្រូវបានចាប់បញ្ជូនដោយអាជ្ញាធរបរទេសតាមច្រកព្រំដែន

- **អគ្គនាយកដ្ឋានអន្តោប្រវេសន៍អន្តោប្រវេសន៍** បានទទួលពលរដ្ឋខ្មែរ ដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់មកប្រទេសកម្ពុជាវិញ ចំនួន១៤០លើក មនុស្សចំនួន២.៨៤៣នាក់ (ស្រី៩៨១នាក់ កុមារ**២៥៧**នាក់)។ Tha

ក្នុងនោះតាមច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិ ចំនួន២៤លើក មនុស្ស៥៤នាក់ ស្រី២២នាក់ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន១១៣លើក មនុស្ស២.៧៨៤នាក់ (ស្រី៩៥៧នាក់ កុមារ២៥៧នាក់) និងប៉ុស្តិ៍នគរបាលច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-វៀតណាម ចំនួន០៣លើក មនុស្ស០៥នាក់ ស្រី០៤នាក់។

*ស្ថានភាព* ៖

- **ក្រុមការងារអនុវត្តច្បាប់** បានរាយការណ៍ថា មានពលរដ្ឋខ្មែរចំនួន២៥៦នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនពីបទឆ្លងដែនខុសច្បាប់ និងឃាត់ខ្លួនលើសពីរយៈពេល១ខែមុននឹងបញ្ជូនមកកម្ពុជាវិញ។
- **ខេត្តបន្ទាយមានជ័យ** អាជ្ញាធរថៃបានបញ្ជូនពលករខ្មែរត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោមរូបភាព «**និរទេស**» តាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត សរុបមានចំនួន៩០ជើង/រថយន្ត មានមនុស្សចំនួន៣.៣៨១នាក់ ស្រី១.២០៨នាក់ ក្នុងនោះកុមារ៣២០នាក់ កុមារី១៣៤នាក់។ បើប្រៀបធៀបនឹងខែមុន គឺមានការថយចុះចំនួន០៨នាក់ ស្មើនឹង០.២៣%។
  - ចេញតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែតមានចំនួន៨៥១នាក់ តាមច្រករបៀងមាន២.៥៣០នាក់ ក្នុងនោះចេញដោយខ្លួនឯង១.២១៥នាក់ និងតាមគេនាំ ២.១៦៦នាក់។
  - តាមការសម្ភាសន៍៖ កុមារ៩៨នាក់ (កុមារី២៩នាក់) ទៅតាមឪពុកម្តាយ៨៣នាក់ និង១៥នាក់ ទៅតាមបងប្អូន។
- **ខេត្តបាត់ដំបង** បានទទួលពលករខ្មែរដែលអាជ្ញាថៃបញ្ជូនត្រឡប់មកវិញ ចំនួន១២លើក មនុស្សចំនួន៨១១នាក់ ស្រី៣៥៣នាក់ កុមារ១៥នាក់ កុមារី០៨នាក់។
- **ខេត្តប៉ៃលិន** បានទទួលពលករខ្មែរដែលអាជ្ញាថៃបញ្ជូនត្រឡប់មកវិញ ចំនួន៣១លើក មនុស្សចំនួន២៩១នាក់ ស្រី១០៨នាក់។
- **ដោយឡែក** យោងតាមរបាយការណ៍**អគ្គនាយកដ្ឋានអន្តោប្រវេសន៍** បានបង្ហាញថាមានជនបរទេសធ្វើការនៅកម្ពុជាដោយខុសច្បាប់ ត្រូវបានរកឃើញដូចខាងក្រោម ៖

១-<u>ការងារអនុវត្តនីតិវិធី និងការបណ្តេញចេញជនបរទេសខុសច្បាប់</u>: ជនបរទេសដែល ល្មើសច្បាប់ស្តីពីអន្តោប្រវេសន៍ ត្រូវបានបណ្តេញពីព្រះរាជាណាចក្រកម្ពុជា មានចំនួន៦១លើក មនុស្សចំនួន៧២នាក់ ស្រី០៥នាក់ មាន២៥សញ្ជាតិ ត្រូវបានបណ្តេញចេញដោយ ៖

- អគ្គនាយកដ្ឋានអន្តោប្រវេសន៍ ចំនួន៣១លើក មនុស្ស៣៨នាក់ ស្រី០៤នាក់ មាន១៦សញ្ជាតិ។
- បដិសេធមិនឲ្យចូលប្រទេសតាមប៉ុស្តិ៍ច្រកទ្វារព្រំដែនអន្តរជាតិ និងក្រុមផ្តល់ទិដ្ឋាការ ចំនួន៣០លើក មនុស្ស៣៤នាក់ មាន១៧សញ្ជាតិ។

២-បទល្មើសស្នាក់នៅខុសច្បាប់ ៖

- ករណីស្នាក់នៅគ្មានលិខិតឆ្លងដែន មនុស្ស០២នាក់ មាន០២សញ្ជាតិ(ឥណ្ឌា និងអ៊ីតាលី)។
- ករណីលួចស្នាក់នៅលើកទិដ្ឋាការ មនុស្ស១០នាក់ មាន០៣សញ្ជាតិ (នីហ្សេរីយ៉ា០៧នាក់ អ៊ុយក្រែន០២នាក់ ចិនដីគោក០១នាក់)។
- ករណីប្រើប្រាស់ឯកសារក្លែងក្លាយ មនុស្ស០២នាក់ មាន០២សញ្ជាតិ (ណាមីប៊ី និងឥណ្ឌា)។ tha

ខ.៦-ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរនិងជនបរទេស

ក្រុមការងារច្រកចេញចូលតែមួយ ទទួលបន្ទុកការងារអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស ជាពិសេស នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើការសម្ភាសពលរដ្ឋខ្មែរ និងជនបរទេសចំនួន១១៨គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់។ បានទំនាក់ទំនងទៅនារីខ្មែរចំនួន១១នាក់ ដែលទៅរស់នៅជាមួយស្វាមីឯក្រៅប្រទេសតាមរយៈទូរស័ព្ទផ្ទាល់ ដើម្បីតាមដានស្ថានភាពដែលសង្ស័យថាអាចកើតមានការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍។

## គ.ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះ ទទួលបានពីអង្គភាពចំនួន៨ គឺ៖ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋានរាជធានី-ខេត្ត (រាជធានីភ្នំពេញ បន្ទាយមានជ័យ បាត់ដំបង កណ្តាល សៀមរាប និងខេត្តត្បូងឃ្មុំ)។

### គ.១-ការងារអនុវត្តច្បាប់

គ.១.១-<u>ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ</u>

អគ្គស្នងការដ្ឋាននគរបាលជាតិ (**ក្រុមការងារអនុវត្តន៍ច្បាប់**) ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានខិតខំតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ បានចំនួន១៣/១៤ករណី (បើប្រៀបធៀបនឹងខែមុនថយចុះ០១ករណី) ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូង ចំនួន២៣នាក់ (ស្រី០៥នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន០៣នាក់ និងជនបរទេស១០នាក់ មាន០៥សញ្ជាតិ (កាណាដា០២នាក់ អង់គ្លេស០៥នាក់ ណាកវេស០១នាក់ នីដឺឡែន០១នាក់ និងញ៉ូហ្សេលែន០១នាក់)។ យើងបានសង្គ្រោះជនរងគ្រោះចំនួន១៩នាក់ មានអាយុក្រោម១៥ឆ្នាំ០៨នាក់ អាយុពី១៥-១៧ឆ្នាំ០៤នាក់ និងអាយុ១៨ឆ្នាំឡើង០៧នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច០៩នាក់ និងគ្រួសារចំនួន១០នាក់)។

**១.ករណីអំពើជួញដូរមនុស្ស៖**

បង្ក្រាបបាន០២/០៤**ករណី** (ថយចុះ០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន០២នាក់ (ស្រី០១នាក់) សង្គ្រោះជនរងគ្រោះចំនួន០២នាក់ ក្នុងនោះមាន៖ អាយុក្រោម១៥ឆ្នាំ០១នាក់ និងអាយុ១៨ឆ្នាំឡើង០១នាក់ (ប្រគល់ឲ្យគ្រួសារទាំងអស់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ |
|---|---|---|
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០១ | ០១ |
| -អំពើលក់ដូរមនុស្សដោយមានគោលដៅ | ០១ | ០១ |
| *សរុប* | *០២ ករណី* | *០២ នាក់* |

**២.អំពើធ្វើអាជីវកម្មផ្លូវភេទ៖**

បង្ក្រាបបាន១១/១០**ករណី** (កើន០១ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន២១នាក់ (ស្រី០៤នាក់) ជនបរទេស១០នាក់ មាន០៥សញ្ជាតិ (កាណាដា០២នាក់ អង់គ្លេស០៥នាក់ ណាកវេស០១នាក់ នីដឺឡែន០១នាក់ tha

និងញ៉ូហ្សេលែន០១នាក់)។ សង្គ្រោះជនរងគ្រោះចំនួន១៧នាក់ ក្នុងនោះមាន៖ អាយុក្រោម១៥ឆ្នាំ០៧នាក់ អាយុ ១៥-១៧ឆ្នាំ០៤នាក់ និងអាយុ១៨ឆ្នាំឡើង០៦នាក់ (ប្រគល់ឲ្យមន្ទីរសង្គមកិច្ច០៩នាក់ និងទៅគ្រួសារ០៨នាក់)។ ដូចមានរាយលម្អិតក្នុងតារាងខាងក្រោម៖

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស |
|---|---|---|---|
| -សញ្ចារកម្ម | ០១ | ០១ | |
| -ស្ថានទម្ងន់ទោសនៃសញ្ចារកម្ម | ០១ | ០២ | |
| -រូបភាព និងសម្ភារៈអាសអាភាស | ០២ | ១១ | កាណាដា២ អង់គ្លេស៥ |
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៥ | ០៥ | ណាកវេស១ នីដីឡែន១ |
| -អំពើអាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០២ | ០២ | ញ៉ូហ្សេលែន១ |
| *សរុប* | *១១ ករណី* | *២១ នាក់* | *១០ នាក់* |

## ឃ.កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

ឃ.១-ការសម្ភាសពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញារងគ្រោះ និងជនសង្ស័យ

- យោងស្ថិតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានបញ្ជូនពលរដ្ឋខ្មែរតាមរយៈស្ថានទូតស្ថានតំណាងនៅបរទេស ដែលសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស មានចំនួន៣៤នាក់ (ស្រី២៣នាក់) មកពី ៖

- ប្រទេសថៃ ចំនួន១៥នាក់ (ស្រី០៩នាក់)
- ប្រទេសម៉ាឡេស៊ី ចំនួន១១នាក់ (ស្រី០៦នាក់)
- ប្រទេសចិន ចំនួន០៦នាក់ (ស្រី០៦នាក់)
- ប្រទេសសឹង្ហបូរី ចំនួន០២នាក់ (ស្រី០២នាក់)។

*ស្ថាប័ន-អង្គភាពអនុវត្តមាន* ៖

- អគ្គស្នងការដ្ឋាននគរបាលជាតិ (របាយការណ៍តាមក្រុមការងារអនុវត្តន៍ច្បាប់) បានទទួលពលករខ្មែររងគ្រោះចំនួន២៣នាក់(ស្រី០៧នាក់) ក្នុងនោះមកពីប្រទេសម៉ាឡេស៊ី១៣នាក់(ស្រី០២នាក់) ថៃ០៥នាក់ ចិន០៤នាក់(ស្រី) និងប្រទេសអារ៉ាប៊ីសាអូឌី០១នាក់(ស្រី)។ តាមការសម្ភាស មានទៅតាមមេខ្យល់១៨នាក់ និងទៅដោយខ្លួនឯង០៥នាក់។

### ឃ.២-ការទទួលជនសង្ស័យរងគ្រោះ

យោងរបាយការណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ក្រុមការងារការពារជនរងគ្រោះ) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយមានកិច្ចសហការជាមួយអង្គការដៃគូ បានទទួលជនរងគ្រោះដែលធ្វើមាតុភូមិនិវត្តន៍ពីប្រទេសនានាសរុបចំនួន២៦នាក់ (ស្រី១៤នាក់)។ មានដូចខាងក្រោម៖

- បានទទួលជនមាតុភូមិនិវត្តន៍កម្ពុជាមកពីប្រទេសនានា និងធ្វើការសម្ភាសកំណត់អត្តសញ្ញាណរកមុខសញ្ញាជនរងគ្រោះដោយបឋមចំនួន១២នាក់ (ស្រី១០នាក់) មកពី៖ ប្រទេសចិន០៧នាក់ ម៉ាឡេស៊ី០៣នាក់ tha

វៀតណាម០១នាក់ និងប្រទេសអារ៉ាប់ប៊ីសាអូឌីត០១នាក់។ ក្នុងនោះមានករណីជួញដូរផ្លូវភេទ០៨នាក់(ស្រី) និងជួញដូរកម្លាំងពលកម្ម០៤នាក់ (ស្រី០២នាក់)។

- **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានទទួល និងធ្វើការសម្ភាសន៍កំណត់អត្តសញ្ញាណប្រជាពលរដ្ឋនីទេសពីប្រទេសថៃ ដើម្បីកមុខសញ្ញាជនរងគ្រោះ និងងាយរងគ្រោះចំនួន១៤នាក់ (ស្រី០៤នាក់ កុមារ១០នាក់ កុមារី០៥នាក់)។ ក្នុងនោះមាន៖ ជនងាយរងគ្រោះ១៣នាក់ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម០១នាក់(កុមារា)។

**ឃ.៣-ការជួយជនរងគ្រោះ និងជនងាយរងគ្រោះ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរមនុស្ស**

យោងរបាយការណ៍ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (**ក្រុមការពារជនរងគ្រោះ**) និងមន្ទីរសង្គមកិច្ចរាជធានី-ខេត្ត ដោយបានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូ ក្នុងការជួយ និងសមាហរណកម្មជនរងគ្រោះដោយអំពើជួញដូរ ទៅតាមសហគមន៍វិញ សរុបចំនួន៤៩នាក់ (ស្ត្រី៣២នាក់)។ ក្នុងនោះមាន៖

- **មជ្ឈមណ្ឌលសំចតប៉ោយប៉ែត** បានបញ្ជូនជនរងគ្រោះ និងងាយរងគ្រោះទាំង១៤នាក់ ទៅទទួលសេវាស្នាក់នៅអប់រំក្នុង និងក្រៅប្រព័ន្ធបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈផ្សេងៗ) នៅអង្គការដៃគូដូចជា៖ អង្គការកម្ពុជាដើម្បីជួយស្ត្រីមានវិបត្តិ (CWCC) ០៩នាក់ អង្គការក្តីសង្ឃឹម និងយុត្តិធម៌(Hope for Justice) ០៣នាក់ និងអង្គការដំណក់ទឹក០២នាក់។
- ជនរងគ្រោះដោយអំពើជួញដូរមនុស្សត្រូវបានសមាហរណកម្មទៅគ្រួសារ និងសហគមន៍វិញចំនួន៣៥នាក់ (ស្ត្រី៣២នាក់) ក្នុងនោះមាន៖ ករណីជួញដូរផ្លូវភេទចំនួន៣២នាក់ និងជួញដូរកម្លាំងពលកម្ម០៣នាក់។

## II. ការលើកកម្ពស់សមត្ថភាព

### ១. ក្នុងប្រទេស

**១.១-ការបណ្តុះបណ្តាលក្នុងប្រទេស**

លេខាធិការដ្ឋាន គ.ជ.ប.ជ ខេត្ត នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន០៣ គឺមានខេត្តព្រះសីហនុ ក្រចេះ និងខេត្តរតនគិរី បានសហការជាមួយជំនាញតាមក្រសួង មន្ទីរ អង្គភាព និងអង្គការដៃគូ បើកវគ្គបណ្តុះបណ្តាលបានចំនួន០៥វគ្គ មានសិក្ខាកាមចូលរួមចំនួន២៣៨នាក់ ក្នុងនោះមានស្ត្រី១៦៧នាក់ ដើម្បីពង្រឹងសមត្ថភាពគ្រូបង្គោល មន្ត្រីអនុវត្តន៍ច្បាប់ សមាជិក គ.ជ.ប.ជ លោកគ្រូ អ្នកគ្រូ ប្រតិបត្តិករទេសចរណ៍នៅតាមសណ្ឋាគារ និងប្រជាពលរដ្ឋ មានតារាងលម្អិតខាងក្រោម៖

*តារាងវគ្គបណ្តុះបណ្តាល*

| ល.រ | ស្ថាប័នអនុវត្ត និងវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|---|
| ១ | **មន្ទីរទេសចរណ៍ ខេត្តព្រះសីហនុ** បានបើកវគ្គបណ្តុះបណ្តាលច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធដល់ប្រតិករទេសចរណ៍ និងវិនិយោគិនទេសចរណ៍ចិន បញ្ហាបនិងផ្សព្វផ្សាយក្នុងការចូលរួមទប់ស្កាត់ការជួញដូរស្ត្រី និងកុមារ ការកេងប្រវ័ញ្ចកម្លាំងពលកម្មកុមារ ទេសចរណ៍ផ្លូវភេទ។ | ០១ | ៣៥ | ១១ |
| ២ | **មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រចេះ** បានបើកវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារជនរងគ្រោះ ការទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពាន និងការធ្វើអាជីវកម្មផ្លូវភេទ។ | ០៣ | ១៥៥ | ១០៩ |
| ៣ | **មន្ទីរកិច្ចការនារីខេត្តរតនគិរី** បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីសកម្មភាពថ្នាក់ភូមិដើម្បីទប់ស្កាត់អំពើជួញដូរមនុស្ស និងកិច្ចការពារជនរងគ្រោះ។ | ០១ | ៤៨ | ៤៧ |
| | សរុប | ០៥ | ២៣៨ | ១៦៧ |

tha

**១.៤-ការងារដឹកនាំសម្របសម្រួល កិច្ចប្រជុំ ៖**

សុបការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេស គឺ៦៥លើក មានអ្នកចូលរួមសរុប៦៨០នាក់ មានស្រី២១៦នាក់ ក្នុងនោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ.ជ.ប.ជ ចំនួន៣០លើក ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន ០១លើក អគ្គនាយកដ្ឋានអន្តោប្រវេសន៍ចំនួន១១លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន២៣លើក។ (**ឧបសម្ព័ន្ធទី២**)

## ២. ក្រៅប្រទេស

### ២.១-កិច្ចប្រជុំ

- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញទៅបំពេញបេសកកម្មនៅសហរដ្ឋអាមេរិក ដើម្បីចូលរួមប្រជុំអនុម័តលើឯកសារកតិកាសញ្ញាជាសកល ស្តីពីទេសន្តរប្រវេសន៍ នៅអង្គការសហប្រជាជាតិ នាទីក្រុងញ៉ូវយ៉ក សហរដ្ឋអាមេរិក។

## IV. ការសន្និដ្ឋានវាយតម្លៃ

### ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចការងារជាលទ្ធផលជាគជ័យគួរកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ **០៤ចំណុច** និងវិធានការ **០៦ចំណុច** របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារនេះ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

### ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង និងចំណុចខ្លាំងខាងលើ យើងពិនិត្យឃើញនៅមានចំណុចប្រឈម នឹងសេសសល់មួយចំនួនដូចជា ៖

- ថ្វីត្បិតតែយើងបានបង្កើតក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការ tha

ក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នា ជាប្រព័ន្ធ និងបែងចែកការទួលខុសត្រូវបន្តរហូតចប់ការងារ។

- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឲ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។
- របាយការណ៍សំខាន់ណាស់សម្រាប់ក្រសួង ស្ថាប័ន អង្គភាពបើរបាយការណ៍ល្អ នោះបញ្ជាក់ថាក្រសួង ស្ថាប័ន ឬអង្គភាពនោះមានស្នាដៃសកម្ម ហើយកិត្តិយសក្រសួង ស្ថាប័ន អង្គភាពក៏បានល្អដែរ។ ឧទាហរណ៍ ក្រសួង ស្ថាប័ន ឬអង្គភាព បានធ្វើការងារច្រើនទាក់ទងនឹងការងារអំពើជួញដូរមនុស្ស តែមន្ត្រីធ្វើរបាយការណ៍មិនយល់ ឬមិនបានសរសេរអស់នូវសកម្មភាព និងទិន្នន័យដែល ក្រសួង ស្ថាប័ន ឬអង្គភាពខ្លួនបានធ្វើ ដូច្នេះកិត្តិយស ក្រសួង ស្ថាប័ន អង្គភាពនោះក៏មិនអស់តាមរបាយការណ៍នោះដែរ។

## គ.សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជនត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនិមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឲ្យលេខាធិការដ្ឋាន គ.រ/ខ.ប.ជ រាជធានី/ខេត្ត ល់របាយការណ៍ឲ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ ដើម្បីប្រសិទ្ធភាពការងារ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។
- ស្នើសុំក្រសួងស្ថាប័នអង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេចស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

## ឃ. សន្និដ្ឋាន

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឲ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារៈ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តិនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។ tha

- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែមីនា ឆ្នាំ២០១៨

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឲ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួមគឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាពជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។ល។

៣. រៀបចំផែនការសកម្មភាពជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(ពាក់កណ្តាលអាណត្តិទី២៖២០១៧-២០១៨)។

៤. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៥. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៦. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឲ្យបានដល់ប្រជាពលរដ្ឋ ជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៧. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៨. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។ tha

៩. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

១០. បន្តរៀបចំវិធានការ "**គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី**" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១១. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១២. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

**ទិសដៅបន្ថែម ដែលជាអនុសាសន៍សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ក្នុងកិច្ចប្រជុំឆមាសទី១ នេះ ដែលគប្បីជំរុញអនុវត្ត ឲ្យមានប្រសិទ្ធភាពសម្រាប់ដំណាក់កាលដ៏ចាំបាច់៖**

១៣. ជំរុញអនុវត្តវិធានការ ដែលដាក់ចុះដោយក្រសួងមហាផ្ទៃ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស ក្នុងដំណាក់កាលនៃការជំរុញដំណោះស្រាយភាពស្របច្បាប់ដល់ពលករ ដែលនៅក្នុងប្រទេសថៃ និងការទទួលខុសត្រូវរបស់អាជ្ញាធរ សមត្ថកិច្ចពាក់ព័ន្ធ ក្នុងការជួយដល់ពលករដែលត្រូវបានបញ្ជូនត្រឡប់។

១៤. បង្កើតក្រុមការងារ ពិសេសមួយក្រោមគណៈកម្មការផ្តល់ភាពស្របច្បាប់ ដឹកនាំដោយរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្រាវជ្រាវ អំពីពលករខ្មែរ ដែលមានវត្តមានក្នុងប្រទេសថៃ ស្ថានភាពស្របច្បាប់ ឬមិនស្របច្បាប់ ទីកន្លែងធ្វើការ អាស័យដ្ឋាននៅកម្ពុជា ដើម្បីងាយស្រួល ក្នុងការដោះស្រាយបញ្ហា និងទំនាក់ទំនងអប់រំ ផ្តល់សេវា និងបង្កើនភាពជឿជាក់ដល់រាជរដ្ឋាភិបាល។

១៥. រៀបចំបែងចែកក្រុមនេះ ដោយស្នើសុំបញ្ចូលជាក្រុមដែលមានបេសកកម្មពិសេស ជាអនុព័ន្ធការងារ ក្នុងរយៈពេលខ្លីមួយ ដែលនឹងត្រូវរំសាយវិញ ពេលចប់បេសកកម្ម។

១៦. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃនៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្នមុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ..................ខែ..........ឆ្នាំ.........នព្វស័ក ព.ស ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី.........ខែ..............ឆ្នាំ២០១៨

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

**ជូ ប៊ុនអេង**

**ចម្លងជូន**

- ខុទ្ទកាល័យ សម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារគ.ជ.ប.ជ

-អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## សកម្មភាពផ្សព្វផ្សាយ និងវេទិកាសាធារណៈក្នុងខែកុម្ភៈ ឆ្នាំ២០១៨

| ល.រ | របាយការណ៍ពី | ខ្លឹមសារសកម្មភាព | អង្គភាព-ស្ថាប័នអ្នករៀបចំ | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្រី |
|---|---|---|---|---|---|---|
| 1 | ក្រុមការងារអនុវត្តន៍ច្បាប់ | ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត ផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស។ | ស្នងការដ្ឋាននគរបាលខេត្ត | 714 លើក | 41,284 នាក់ | 20,316 នាក់ |
| 2 | ខេត្តកណ្តាល | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត | 352 លើក | 18,745 នាក់ | 9,982 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកិច្ចការពារជនរងគ្រោះ ដល់ប្រជាពលរដ្ឋ។ | ក្រុមការងារថ្នាក់ស្រុក | 26 លើក | 1,943 នាក់ | 1,077 នាក់ |
| 3 | ខេត្តតាកែវ | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដោយបញ្ជ្រាបក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ និងស្នងការដ្ឋាននគរបាលខេត្ត | 68 លើក | 2,313 នាក់ | 838 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | មន្ទីរកិច្ចការនារីខេត្ត | 133 លើក | 6,121 នាក់ | 2,111 នាក់ |
| 4 | ខេត្តពោធិ៍សាត់ | វេទិកាសាធារណៈ ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងអំពើជួញដូរមនុស្ស ដល់ប្រជាពលរដ្ឋ ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 169 លើក | 6,647 នាក់ | 3,483 នាក់ |
| | | ផ្សព្វផ្សាយតាមរយៈភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅតាមវិទ្យាល័យ អនុវិទ្យាល័យទាំង២០ ទូទាំងខេត្តពោធិ៍សាត់ សិស្សានុសិស្ស និងលោកគ្រូ អ្នកគ្រូ។ | មន្ទីរអប់រំ យុវជន និងកីឡាខេត្ត | 524 លើក | 86,746 នាក់ | 45,482 នាក់ |
| 5 | ខេត្តបាត់ដំបង | ផ្សព្វផ្សាយ ស្តីពី ការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត | 802 លើក | 37,528 នាក់ | 19,686 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្សលើស្ត្រី និងកុមារ ការធ្វើអាជីវកម្មផ្លូវភេទ និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត | 354 លើក | 11,571 នាក់ | 6,116 នាក់ |
| 6 | ខេត្តសៀមរាប | ផ្សព្វផ្សាយ ស្តីពីការអនុវត្តគោលនយោបាយភូម-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ទូទាំងខេត្ត។ | ស្នងការដ្ឋាននគរបាលខេត្ត | 218 លើក | 10,407 នាក់ | 6,368 នាក់ |
| | | ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ដល់ លោកគ្រូ អ្នកគ្រូ សិស្សានុសិស្ស និងប្រជាពលរដ្ឋ។ | រដ្ឋបាលស្រុក និងមន្ទីរអប់រំខេត្ត | 16 លើក | 724 នាក់ | 341 នាក់ |

Thon

| | | | | | | |
|---|---|---|---|---|---|---|
| 7 | ខេត្តកំពង់ឆ្នាំង | វេទិកាសាធារណៈផ្សព្វផ្សាយ ដល់ប្រជាពលរដ្ឋ ស្តីពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាពដល់ប្រជាពលរ។ | ស្នងការដ្ឋាននគរបាលខេត្ត | 465 លើក | 17,013 នាក់ | 8,491 នាក់ |
| | | ផ្សព្វផ្សាយលក្ខណៈសម្បត្តិ៩យ៉ាង អំពីគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព និងផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់ការជួញដូរស្ត្រី និងកុមារដល់ គ.ក.ន.ក យុវវ័យ ក្រុមឪពុកម្តាយកុមារ និងផ្សព្វផ្សាយ ស្តីពីច្បាប់ការងារ ច្បាប់ការបង្ក្រាបអំពើជួញដូរមនុស្ស នៅតាមរោងចក្រ សហគ្រាស ដល់កម្មករ និយោជិក។ | ស្នងការដ្ឋាននគរបាលខេត្ត រដ្ឋបាលស្រុក និងមន្ទីរការងារខេត្ត | 540 លើក | 20,896 នាក់ | 10,497 នាក់ |
| 8 | ខេត្តរតនគិរី | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូម-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត | 52 លើក | 3,530 នាក់ | 1,714 នាក់ |
| | | ផ្សព្វផ្សាយ ទៅដល់ម្ចាស់សហគ្រាស គ្រឹះស្ថាន ក្រុមហ៊ុន សិប្បកម្មនានា ក្នុងខេត្ត ឲ្យអនុវត្តតាមច្បាប់ស្តីពីការងារ។ | មន្ទីរសង្គមការងារខេត្ត | 10 លើក | 95 នាក់ | 54 នាក់ |
| 9 | ខេត្តព្រះសីហនុ | ផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជខេត្ត | 3 លើក | 203 នាក់ | 133 នាក់ |
| | | វេទិកាសាធារណៈ ស្តីពីទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ អាជ្ញាធរ ភូមិ ក្រុមប្រឹក្សាឃុំ/សង្កាត់ លោកគ្រូ អ្នកគ្រូ និងប្រជាពលរដ្ឋ។ | ក្រុមការងារគ.ខ.ប.ជខេត្ត និងអាជ្ញាធរក្រុង/ស្រុក | 4 លើក | 244 នាក់ | 121 នាក់ |
| 10 | ខេត្តកំពង់ចាម | ផ្សព្វផ្សាយ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត និងអង្គការដៃគូ | 627 លើក | 34,760 នាក់ | 17,555 នាក់ |
| | | ផ្សព្វផ្សាយអប់រំ និងផ្តល់ប្រឹក្សាពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | | 1 លើក | 454 នាក់ | 303 នាក់ |
| 11 | ខេត្តកោះកុង | វេទិកាសាធារណៈ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត | 32 លើក | 1,625 នាក់ | 905 នាក់ |
| 12 | ខេត្តក្រចេះ | ផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកិច្ចការពារជនរងគ្រោះដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 2 លើក | 90 នាក់ | 79 នាក់ |
| 13 | ខេត្តស្វាយរៀង | វេទិកាសាធារណៈ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត | 373 លើក | 13,117 នាក់ | 7,317 នាក់ |
| 14 | ខេត្តព្រះវិហារ | ផ្សព្វផ្សាយតាមរយៈគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាពដល់ប្រជាពលរដ្ឋ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 2 លើក | 242 នាក់ | 109 នាក់ |
| 15 | ខេត្តត្បូងឃ្មុំ | វេទិកាសាធារណៈ តាមរយៈគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព។ | លេខាធិការដ្ឋាន គ.ខ.ប.ជ | 5 លើក | 206 នាក់ | 142 នាក់ |



the

| | | | | | | |
|---|---|---|---|---|---|---|
| 16 | ខេត្តស្ទឹងត្រែង | ផ្សព្វផ្សាយ ស្តីពីជំរកសុវត្ថិភាពសម្រាប់ស្ត្រី និងក្មេងស្រី លើការរំលោភបំពាន ដល់ប្រជាពលរដ្ឋ។ | មន្ទីរកិច្ចការនារីខេត្ត | 1 លើក | 180 នាក់ | 104 នាក់ |
| 17 | ខេត្តកែប | ផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈ គោលនយោបាយភូម-ឃុំមានសុវត្ថិភាព ដល់ប្រជាពលរដ្ឋ។ | លេខាធិការដ្ឋាន គ.ខ.ប.ជ ស្នងការដ្ឋាននគរបាលខេត្ត | 18 លើក | 5,256 នាក់ | 2,543 នាក់ |
| 18 | ខេត្តកំពង់ស្ពឺ | ផ្សព្វផ្សាយ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងកិច្ចការពារជនរងគ្រោះ ដល់ ប្រជាពលរដ្ឋ។ | អធិការដ្ឋានក្រុង ស្រុក និង អាជ្ញាធរមូលដ្ឋាន | 12 លើក | 1,882 នាក់ | 927 នាក់ |

សកម្មភាពសរុបចំនួន: 5,523 លើក

មនុស្សសរុបចំនួន: 323,822 នាក់

ស្រីសរុបចំនួន : 166,794 នាក់

tha

## ឧបសម្ព័ន្ធទី២

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន៦៥លើក) មនុស្សចំនួន៦៨០នាក់ (ស្រី២១៦នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
| --- | --- |
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | សម្របសម្រួលចំនួន៣០លើក អ្នកចូលរួមសរុបចំនួន៣២៦នាក់ (ស្រី៣២នាក់)<br>❖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ៖<br>- បានអញ្ជើញជាអធិបតី ក្នុងពិធីបើកសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការតាមដានត្រួតពិនិត្យ នៃការអនុវត្តក្រមប្រតិបត្តិយេនឌ័រ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ នៅសណ្ឋាគារ កាំបូឌីយ៉ាណា មានសមាសភាពចូលរួមប្រមាណ ១៥០នាក់។<br>- បានដឹកនាំកិច្ចប្រជុំលើសេចក្តីព្រាងអនុស្សរណៈយោគយល់គ្នា រវាងអង្គការ GVP (GRUPPO DI VOLONTARIATO CIVILE) និងគ.ជ.ប.ជ ស្តីពីការគាំទ្រ និងការតស៊ូមតិ លើសិទ្ធិពលករទេសន្តប្រវេសន៍កម្ពុជា និងប្រទេសថៃ ក្នុងការបង្ការទប់ ស្កាត់ពីការរំលោភបំពានផ្សេងៗ និងអំពើជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន។<br>- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ត្រៀមរៀបចំកិច្ចប្រជុំ ស្តីពីកិច្ចការពារពលករទេសន្តប្រវេសន៍៖ តួនាទីប្រទេសបញ្ជូននិងប្រទេសទទួល នៅទីស្តីការក្រសួងមហាផ្ទៃ មានសមាសភាពចូលរួមចំនួន៦០នាក់ ស្រី១៩នាក់។<br>- បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុងអគ្គលេខាធិការដ្ឋាន ស្តាប់របាយការណ៍ និងពិភាក្សាលើការវាយតម្លៃរាជធានី-ខេត្ត នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សា ជាមួយតំណាងក្រសួង ស្ថាប័ន និងអង្គការដៃគូពាក់ពន្ធ័ ដើម្បីពិនិត្យ និងសម្រេចលើរបាយការណ៍ឆ្នាំ២០១៧-នៅទីស្តីការក្រសួងមហាផ្ទៃ មានសមាសភាពចូលរួមចំនួន៥៨នាក់។<br>- បានអញ្ជើញចុះអនុស្សរណៈនៃការយោគយល់គ្នា រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងសមាគមមូលនិធិ **ឈាន ឆាយ** ដើម្បីមនុស្សធម៌ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ជាពិសេសក្នុងចំណោមពលករទេសន្តប្រវេសន៍នៅប្រទេសថៃ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន។<br>- បានឹកនាំកិច្ចប្រជុំអន្តរក្រសួង រៀបចំយុទ្ធសាស្ត្រជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សឆ្នាំ២០១៩-២០២៣ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន។<br>- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ពិភាក្សាត្រៀមរៀបចំប្រជុំ ស្តីពីកិច្ចការពារ ពលករទេសន្តប្រវេសន៍: តួនាទីប្រទេសបញ្ជូន និងប្រទេសទទួល នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន មានសមាសភាពចូលរួមចំនួន២៦នាក់ ស្រី០៦នាក់។<br>- បានរៀបចំកិច្ចប្រជុំពិភាក្សា ជាមួយអង្គការដៃគូក្នុងការរៀបចំគម្រោងបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database) សម្រាប់គ្រប់គ្រង និងត្រួតពិនិត្យទិន្នន័យជនរងគ្រោះដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់អង្គការ ដែលមានអ្នកចូលរួមចំនួន១៣នាក់ ស្រី០៤នាក់។<br>❖ ឯកឧត្តម នាយឧត្តមសេនីយ៍ **ថោង សំអាត** អគ្គលេខាធិការ គ.ជ.ប.ជ ៖<br>- បានអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៨ របស់រដ្ឋបាលខេត្តព្រះសីហនុ។ |

| | |
|---|---|
| | - បានអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៨ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៨ របស់រដ្ឋបាលខេត្តកណ្តាល។<br>- បានអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៨ របស់រដ្ឋបាលរាជធានីភ្នំពេញ។<br>- បានអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៨ របស់រដ្ឋបាលខេត្តកំពង់ចាម។<br>- បានអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៨ របស់រដ្ឋបាលខេត្តត្បូងឃ្មុំ។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំ ស្តីពីការកំណត់ចំនួនមុខតំណែងថ្នាក់អគ្គនាយករង អនុនាយកដ្ឋាន អនុការិយាល័យ និងថ្នាក់ប្រហាក់ប្រហែលនៃក្របខ័ណ្ឌនគរបាលជាតិមន្ត្រីរាជការស៊ីវិល និងមន្ត្រីពន្ធនាគារ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារសម្រាប់អនុវត្តឆ្នាំ២០១៨ របស់រដ្ឋបាលខេត្តតាកែវ។<br>- បានដឹកនាំកិច្ចប្រជុំផ្ទៃក្នុង ស្តីពីការត្រួតពិនិត្យ កែសម្រួលរបាយការណ៍ ត្រៀមធ្វើសន្និបាតប្រចាំឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ រួមទាំងប្រលងប្រឆាំងសេប់រាជធានី-ខេត្ត មានសមាសភាពចូលរួមចំនួន១៦នាក់ ស្រី០១នាក់។<br>- បានអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានកស្តុការនិងហិរញ្ញវត្ថុ នៅសាលប្រជុំក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ របស់អគ្គនាយកដ្ឋានអន្តោប្រវេសន៍ នៅសាលប្រជុំក្រសួងមហាផ្ទៃ។<br>- បានដឹកនាំត្រួតពិនិត្យវត្តមាន វិន័យ និងសណ្តាប់ធ្នាប់មន្ត្រីនគរបាលជាតិ និងមន្ត្រីស៊ីវិល នៃអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ រៀងរាល់សប្តាហ៍ច្ចៃច័ន្ទ។<br><br>❖ **ក្រុមជំនួយកិច្ចការទាំង០៦ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ៖**<br>- ឯកឧត្តម ឧត្តមសេនីយ៍ទោ **ជីវ ផល្លី** អគ្គលេខាធិការរង ដឹកនាំប្រជុំក្នុងក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ ស្តីពីការពិនិត្យលើអាទិភាពផែនការសកម្មភាពសម្រាប់អនុវត្តឆ្នាំ២០១៨ មានសមាសភាពចូលរួមចំនួន០៧នាក់ ស្រី០១នាក់។<br>- លោកឧត្តមសេនីយ៍ត្រី ***កែវ សុវណ្ណារ៉ា*** ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានអញ្ជើញជួបសម្របសម្រួលជាមួយនាយកដ្ឋានទំនាក់ទំនងអន្តរជាតិក្រសួងមហាផ្ទៃ ស្តីពីការស្នើទិដ្ឋាការជូន **លោកជំទាវអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ.** ដើម្បីចូលរួមកិច្ចប្រជុំ ស្តីពីទេសន្តរប្រវេសន៍ នៅទីក្រុងញូវយ៉ក សហរដ្ឋអាមេរិក។<br>- បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយផែនការយុទ្ធសាស្ត្រឆ្នាំ២០១៨-២០២០ សម្រាប់ក្រុមយុវជនជំទង់ និងយុវជន រៀបចំដោយសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ នៅសណ្ឋាគារសាន់វ៉េ។<br>- បានចូលរួមកិច្ចប្រជុំ ស្តីពីការចាត់តំណាង ដើម្បីទៅចូលរួមកិច្ចប្រជុំលើកទី១០ នៅទីក្រុងប្រ៊ុចសែល ប្រទេសបែលហ្សិក ចាប់ពីថ្ងៃទី ១២-១៤ ខែមីនា ឆ្នាំ២០១៨ នៅទីស្តីការក្រសួងការបរទេស។ |

Tho

| | |
|---|---|
| | - លោកជំទាវ រ៉ន **សិរីលក្ខិណា** អគ្គលេខាធិការរង បានអញ្ជើញចូលរួម កិច្ចប្រជុំបូកសរុបការងារឆ្នាំ២០១៧ និងទិសដៅការងារឆ្នាំ២០១៨ របស់ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ និងក្រុមការងារខមមីត កម្ពុជា នៅទីស្តីការក្រសួងកិច្ចការនារី។<br>- លោកជំទាវ រ៉ន **សិរីលក្ខិណា** អគ្គលេខាធិការរង បានដឹកនាំកិច្ចប្រជុំជាមួយអង្គការចាប់ដៃ ស្តីពីការបន្ថែម និងកែប្រែចំណុចមួយចំនួនទៅលើសេចក្តីព្រាងអនុស្សរណៈ រវាង គ.ជ.ប.ជ និងអង្គការចាប់ដៃ ទៅលើការកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យបច្ចុប្បន្នភាពរបស់អង្គការ ដៃគូអភិវឌ្ឍន៍។<br>- លោកជំទាវ រ៉ន **សិរីលក្ខិណា** អគ្គលេខាធិការរង បានដឹកនាំកិច្ចប្រជុំជាមួយអង្គការចាប់ដៃ ស្តីពីការគ្រប់គ្រងប្រព័ន្ធទិន្នន័យអង្គការ និងការផ្តល់ឱកាសសម្រាប់ផលិតវីដេអូខ្លីពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស និងការលើកឱកាសថ្មីសម្រាប់ការធ្វើសិក្ខាសាលាបណ្តុះបណ្តាល និងពង្រឹងការងារអនុវត្តច្បាប់ និងការងារយុត្តិធម៌នៅថ្នាក់ខេត្ត ដើម្បីជំរុញការសហការរវាងនគរបាល និង ព្រះរាជអាជ្ញា នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន។<br>- បានប្រជុំក្នុងក្រុមជំនួយកិច្ចការបូកសរុប និងធ្វើរបាយការណ៍ឆ្នាំ២០១៧ របស់ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើសមាហរណកម្មចិត្តសង្គម IOM នៅទន្លេបាក់សាក់២។ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | - បានរៀបចំកិច្ចប្រជុំពិភាក្សា ជាមួយអង្គការដៃគូក្នុងការរៀបចំគម្រោងបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យ (Database) សម្រាប់គ្រប់គ្រង និងត្រួតពិនិត្យទិន្នន័យជនរងគ្រោះដែលស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់អង្គការ ដែលមានអ្នកចូលរួមចំនួន១៣នាក់ (ស្រី០៤នាក់)។ |
| អគ្គនាយកដ្ឋានអន្តោប្រវេសន៍ | ❖ ឯកឧត្តម នាយឧត្តមសេនីយ៍បណ្ឌិត សុខ ផល អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានអញ្ជើញចូលរួមចំនួន១១លើក៖<br>- បានអញ្ជើញចូលរួមក្នុងពិធីបិទសន្និបាតបូកសរុបវឌ្ឍនភាព នៃការងារអត្តសញ្ញាណកម្ម និងលើកទិសដៅអនុវត្តបន្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំអគារ(A) ទីស្តីការក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំសាលមហោស្រពស្ទឹងសង្កែ ខេត្តបាត់ដំបង។<br>- បានអញ្ជើញចូលរួមបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំសាលាខេត្តបន្ទាយមានជ័យ។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំការងារវិសោធនកម្មរដ្ឋធម្មនុញ្ញ និងក្រមព្រហ្មទណ្ឌ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំអគារ(A) ទីស្តីការក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមប្រជុំពិភាក្សា និងចុះហត្ថលេខាលើផែនការសហប្រតិបត្តិការឆ្នាំ២០១៨ ក្រោមអធិបតីភាព សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង ឯកឧត្តម ឧត្តមសេនីយ៍ឯក **បម្រុង តូឡឹម** រដ្ឋមន្ត្រីក្រសួងនគរបាល នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។<br>- បានអញ្ជើញចូលរួមកិច្ចប្រជុំ ស្តីពីការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរពីសហរដ្ឋអាមេរិក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំអគារ(A) ទីស្តីការក្រសួងមហាផ្ទៃ។ |

| | |
|---|---|
| | - បានអញ្ជើញចូលរួមបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំសាលាខេត្តកណ្ដាល។<br>- បានអញ្ជើញចូលរួមបិទសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០១៧ និងលើកទិសដៅការងារឆ្នាំ២០១៨ របស់រដ្ឋបាលរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំរាជធានីភ្នំពេញ។<br>- បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ ស្ដីពីបញ្ហាពាក់ព័ន្ធសមាគន និងអង្គការមិនមែនរដ្ឋាភិបាល (NGO) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំអគារ(A) ទីស្ដីការក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំ ស្ដីពីអន្តោប្រវេសន៍ជនជាតិចិន ដែលកំពុងស្នាក់នៅ និងធ្វើអាជីវកម្មនៅខេត្តព្រះសីហនុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំអគារ(A) ទីស្ដីការក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមការងារអន្តរក្រសួងចុះសិក្សាស្ថានភាពតាមបណ្ដាប៉ុស្ដិ៍ច្រកទ្វារព្រំដែន ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្ដេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំអគារ(A) ទីស្ដីការក្រសួងមហាផ្ទៃ។ |
| **លេខាធិការដ្ឋាន គ.ខ.ប.ជ សម្របសម្រួលចំនួន២៣លើក អ្នកចូលរួមសរុបចំនួន៣៤១នាក់ (ស្រី១៨០នាក់)** | |
| ខេត្តកណ្ដាល | សម្របសម្រួលចំនួន១០លើក អ្នកចូលរួមចំនួន២១៥នាក់ ស្រី១១២នាក់<br>- ក្រុមការងារថ្នាក់ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែ ចំនួន០៨លើក អ្នកចូលរួមចំនួន១៨០នាក់ ស្រី៩០នាក់។<br>- គណៈកម្មាធិការ និងលេខាធិការដ្ឋានខេត្ត បានរៀបចំកិច្ចប្រជុំបូកសរុបការងារប្រចាំខែ អ្នកចូលរួមចំនួន៣៥នាក់ ស្រី២២នាក់។<br>- លោកអភិបាលស្រុក និងជាប្រធានក្រុមការងារប្រយុទ្ធប្រឆាំងជួញដូរមនុស្សស្រុកលើកដែក ចូលរួមជាអធិបតីបើកកិច្ចប្រជុំ ស្ដីពីការលុបបំបាត់ប៉ុស្ដិ៍ត្រួតពិនិត្យនៅផ្ទៃក្នុងប្រទេស និងពង្រឹងការអនុវត្តច្បាប់ផ្សព្វផ្សាយត្រួតពិនិត្យការចរាចរណ៍ឆ្លងដែន ក្នុងន័យទប់ស្កាត់អំពើជួញដូរមនុស្ស និងរត់ពន្ធមនុស្សខុសច្បាប់។ |
| ខេត្តបាត់ដំបង | - បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ប្រមូលធាតុចូលសម្រាប់រៀបចំកិច្ចប្រជុំពិភាក្សា ស្ដីពីក្រុមប្រទេសបញ្ជូន កម្ពុជា ឡាវ មីយ៉ាន់ម៉ា អំពីបញ្ហារួមគ្នា និងដំណោះស្រាយ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្ដីការក្រសួងមហាផ្ទៃ។ |
| ខេត្តសៀមរាប | - រដ្ឋបាលស្រុកជីក្រែង បានសហការជាមួយអង្គការក្រុមអ្នកស្ម័គ្រចិត្តសង្គមស៊ីវិល (GVC) បានប្រជុំជាមួយទ្វេភាគីចម្រុះចំនួន០៥ឃុំ ដែលមានអ្នកចូលរួមចំនួន២៩នាក់ ដែលបានពិភាក្សាលើការជ្រើសរើសបណ្ណាញសុច្ចនៈរបស់អង្គការក្រុមអ្នកស្ម័គ្រចិត្ត(GVC) ដែលជ្រើសរើសយកពីអតីតភាពពលករ និងបានសម្រេចជ្រើសរើសយកអតីតភាពពលករលោតពីលើទូកអ្នកសាទនៅប្រទេសថៃកាលពីឆ្នាំ២០១៧។ |
| ខេត្តព្រះវិហារ | - កិច្ចប្រជុំអំពីការពិភាក្សា ជាមួយក្រុមការងារទាំង០៦ របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត ជំរុញឲ្យក្រុមការងារទាំង០៦ ធ្វើផែនការតាមជំនាញរៀងខ្លួន ក្នុងឆ្នាំ២០១៨ ដើម្បីអនុវត្តន៍សកម្មភាព ធ្វើការងារផ្សព្វផ្សាយដល់ប្រជាពលរដ្ឋបន្ត ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ និងជោគជ័យ អ្នកចូលរួមចំនួន២២នាក់ ស្រី១១នាក់។ |

Tha

| | |
|---|---|
| ខេត្តប៉ៃលិន | - បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ប្រមូលធាតុចូលសម្រាប់រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីក្រុមប្រទេសបញ្ជូន កម្ពុជា ឡាវ មីយ៉ាន់ម៉ា អំពីបញ្ហារួមគ្នា និងដំណោះស្រាយ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- ចូលរួមសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ក្រោមជាតិលើសេចក្តីព្រាងរបាយការណ៍ជាតិគួបផ្សំលើកទី៤ ទី៥ ទី៦ សម្រាប់ផ្ញើជូនគណៈកម្មាធិការសិទ្ធកុមារ នៃអង្គការសហប្រជាជាតិ។ |
| ខេត្តព្រៃវែង | - បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ប្រមូលធាតុចូលសម្រាប់រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីក្រុមប្រទេសបញ្ជូន កម្ពុជា ឡាវ មីយ៉ាន់ម៉ា អំពីបញ្ហារួមគ្នា និងដំណោះស្រាយ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។ |
| ខេត្តកំពង់ធំ | - បានចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ប្រមូលធាតុចូលសម្រាប់រៀបចំកិច្ចប្រជុំពិភាក្សា ស្តីពីក្រុមប្រទេសបញ្ជូន កម្ពុជា ឡាវ មីយ៉ាន់ម៉ា អំពីបញ្ហារួមគ្នា និងដំណោះស្រាយ ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានចូលរួមសិក្ខាសាលា ស្តីពីការត្រួតពិនិត្យ តាមដានការអនុវត្តក្រុមប្រតិបត្តិយេនឌ័រ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ។<br>- បានចូលរួមប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០១៧ និងលើកទិសដៅការងារក្នុងឆ្នាំ២០១៨ របស់ក្រុមប្រឹក្សាជាតិដើម្បីស្ត្រី នៅវិមានសន្តិភាព ទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ខេត្តស្ទឹងត្រែង | - មន្ត្រីកិច្ចការនារីខេត្ត បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពីសកម្មភាពថ្នាក់ភូមិ ដើម្បីទប់ស្កាត់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចនានា នៅខេត្តរតនគិរី។ |
| ខេត្តតាកែវ | - លោកស្រីអភិបាលរងខេត្ត បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយពង្រឹងការងារជួញដូរ និងចំណាកស្រុក នៅស្រុកគិរីវង់។ |
| ខេត្តមណ្ឌលគិរី | - បានចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការតាមដានត្រួតពិនិត្យ ការអនុវត្តក្រុមប្រតិបត្តិការងារយេនឌ័រក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅរាជធានីភ្នំពេញ។ |
| ខេត្តឧត្តរមានជ័យ | - បានចូលរួមកិច្ចប្រជុំ គ ក ស ក នៅសាលាខេត្ត មានអ្នកចូលរួមចំនួន២៥នាក់ ស្រី១១នាក់។<br>- បានចូលរួមវគ្គបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់តំបន់ ស្តីពីការបង្ការ ទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ មានអ្នកចូលរួមចំនួន៥០នាក់ ស្រី៤៦នាក់។ |

Tha